

# របាំអង្រែ

កសិកម្មជាមូលដ្ឋានដ៏សំខាន់មួយនៅក្នុងបណ្ដាប្រទេស មានកម្ពុជា ថៃឡង់ដ៍ ឡាវ ឥណ្ឌូណេស៊ី និងហ្វីលីពីនៗលៗ ដូច្នេះកសិកម្មនៅក្នុងទម្រង់ផ្សេងៗគ្នាត្រូវបានគេយកជាមូលដ្ឋាន ដើម្បីបង្កើតនិងអភិវឌ្ឍស្នាដៃសិល្បៈជាដើម នៅក្នុងបណ្ដាប្រទេសខាងលើនេះ។

នៅកម្ពុជា គេប្រើអង្រែនិងត្បាល់តាមបែបបុរាណ ដើម្បីនឹងបុកស្រូវយកអង្ករ។ អ្នកបុកពីរនាក់ ម្នាក់ដៃម្ខាងកាន់អង្រែ បុកឆ្លាស់គ្នាទៅក្នុងត្បាល់ជាចង្វាក់ជាមូលដ្ឋានដែល សិល្បករយើងយកមកច្នៃប្រឌិតបង្កើតជារបាំអង្រែនេះឡើង។ របាំអង្រែ មានឈ្មោះផ្សេងៗ គ្នាដែលគេធ្លាប់ហៅ មានរបាំអង្រែ របាំគោះអង្រែ ឬរបាំរាំអង្រែ។[1]

ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ បានអះអាងថានាសម័យមុន របាំអង្រែមានប្រជាប្រិយភាពនិងមានគេសម្ដែងនៅទូទាំងប្រទេសកម្ពុជា។ របាំអង្រែនេះអាចមានប្រភពដើមពីជនជាតិដើមគួយនៃកម្ពុជា (ដែលគេហៅរបាំនេះថា «របាំគួយ») និងជនជាតិហ្វីលីពីន ដែលបានសម្ដែងថ្វាយព្រះបាទសម្ដេច ព្រះសុវណ្ណកោដ្ឋ នៅពេលដែលព្រះអង្គទ្រង់បានយាងធ្វើព្រះរាជទស្សនកិច្ចនៅទីក្រុងម៉ានីល។ នាពេលនោះ នាដការីរបាំព្រះរាជទ្រព្យដែលអមព្រះរាជ ដំណើរព្រះអង្គ អាចបានរៀនរបាំអង្រែពីហ្វីលីពីន។[2]

## នៅមុនសម័យសង្គ្រាមឆ្នាំ១៩៧៥

---

[1] ចាប ពិន ១៩៦៤: ៥៤, ៦៣, ៦៧

[2] ចាប ពិន ១៩៦៤: ៦៣-៦៥

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង

គេឃើញមានរបាំនេះ សម្តែងតែនៅក្នុងតំបន់មួយចំនួន ដូចជាសម្រោងចុងកាល់ និងជាំក្សាន្តផ្នែកខាងពាយ័ព្យ នៃប្រទេសកម្ពុជា។ ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ ក៏បានអះអាងដែរថា ការសម្តែងរបាំអង្រែនៅសម្រោងចុងកាល់និងជាំក្សាន្តមានយថា-ភាពជាងនៅកន្លែងឯទៀត ទាំងចលនាក្បាច់ សម្លៀកបំពាក់ តន្ត្រី និងចម្រៀង។[៣]

វង់តន្ត្រីដើមដែលគេប្រើសម្រាប់កំដររបាំអង្រែមានឧបករណ៍ខ្សែមួយ១ និងអង្គួច១អមដោយស្គរ និងចង្វាក់នៃអង្រែដែលគេគោះទៅលើកំណល់នៅលើដី។ ទៅតាមការនិយម និងចំណង់ចំណូលចិត្តនៃក្រុមនីមួយៗក្រុមខ្លះមានបន្ថែមស្គរដៃ១ និងក្រាប់១គូឬច្រើនគូថែមទៀតផង។

របាំអង្រែបច្ចុប្បន្នដែលយើងឃើញសព្វថ្ងៃជាស្នាដៃបង្កើតឡើងដោយសិល្បករសិល្បការិនីនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈដែលមានលក្ខណៈផ្សេងពីរបាំរាំអង្រែដើម មានតែការប្រើប្រាស់អង្រែជាឧបករណ៍មួយប៉ុណ្ណោះដែលដូចគ្នា។ ចំពោះស្ថានភាពផ្សេងទៀត ដូចជាបរិបទប្រធានបទ ចលនា ក្បាច់ សម្លៀកបំពាក់ តន្ត្រី និងចម្រៀងត្រូវបានគេបង្កើតថ្មីទាំងអស់។ ហើយរបាំអង្រែ បច្ចុប្បន្នកំដរដោយវង់តន្ត្រីមហោរីវិញ។

ក្នុងរបាំគេយកអង្រែមួយគូៗ ទៅដាក់នៅលើកំណល់ឈើមួយនៅខាងចុងសងខាងរួចអ្នកគោះត្រូវគោះទៅលើកំណល់ជាចង្វាក់តាមភ្លេង។ អ្នករាំជាគូៗ ស្រីមួយប្រុសមួយរាំ ដោយបោះជើងទៅក្នុងចន្លោះអង្រែនិងទៅក្រៅអង្រែ ព្រមទាំងទះដៃទៅតាមចង្វាក់ភ្លេង និងជួនកាលក៏ច្រៀងជាមួយផង។ នៅចុងរបាំភ្លេងក៏ចាប់លេងរន្ថើនលឿនឡើងៗរួចហើយបញ្ចប់របាំភ្លាមៗ។

៣ ចាប ពិន ១៩៦៤: ៦៤-៦៥

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង

KHMER CIVILIZATION





អត្ថបទដោយ៖ បណ្ឌិត សំ សំអាង

## ឯកសារពិគ្រោះ

ចាប ពិន. (១៩៦៤). *របាំប្រជាប្រិយខ្មែរ.* ភ្នំពេញ: ពុទ្ធសាសនបណ្ឌិត្យ។

Sam, Chan Moly, Nguon, Sam Ath, and Sam, Sam-Ang.

1988. *Khmer Folk Dance* (2nd ed.). Washington, DC: Cambodian Network Council.

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION